**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ បព ១២៣/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# បទបង្ហាញស្តីពីវឌ្ឍនភាពនៃការប្រយុទ្ធប្រឆាំងការឆបោក តាមប្រព័ន្ធបច្ចេកវិទ្យា

នៅរសៀលថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៦ **ឯកឧត្តម ផៃ ស៊ីណារិទ្ធ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (គ.ប.ឆ.ប) បានធ្វើបទបង្ហាញជូនសមាជិកអង្គទូត និងអង្គការអន្តរជាតិនានាអំពីការវិវឌ្ឍថ្មីៗនៃការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យារបស់កម្ពុជា។ បទបង្ហាញនេះត្រូវបានសម្របសម្រួលដោយ **លោកជំទាវ អ៊ិត សោភា** រដ្ឋលេខាធិការប្រចាំការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងមានការចូលរួមពីប្រធានបេសកកម្មកម្ពុជានៅក្រៅប្រទេស ផងដែរ។

**ឯកឧត្តម ផៃ ស៊ីណារិទ្ធ** បានថ្លែងអំណរគុណចំពោះស្ថានបេសកកម្មបរទេស និងដៃគូអន្តរជាតិចំពោះកិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់ ក្នុងការដោះស្រាយបញ្ហាឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលឯកឧត្តមបានពិពណ៌នាថាជាទម្រង់ដ៏ស្មុគស្មាញបំផុតមួយនៃឧក្រិដ្ឋកម្មឆ្លងដែន។ ឯកឧត្តមបានបង្ហាញពីវឌ្ឍនភាពសំខាន់ៗ ដែលជាលទ្ធផលនៃយុទ្ធនាការដ៏ខ្លាំងក្លាក្រោមការដឹកនាំដោយផ្ទាល់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត**។ គិតត្រឹមថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៦ អាជ្ញាធរបានឆ្មក់ចូលទីតាំងសង្ស័យជាង ៧៩៣ ទីតាំង ប្រតិបត្តិការបង្ក្រាបការឆបោកបានចំនួន៦២៤ទីតាំង លុបបំបាត់មណ្ឌលឆបោកបានចំនួន៨៦កន្លែង និងឃាត់ខ្លួនជនសង្ស័យជាង២៩.០០០នាក់ មានចំនួន៣៩សញ្ជាតិ។ បុគ្គលជាង២២.០០០នាក់មកពី៣៨ប្រទេស ត្រូវបានចាប់បញ្ជូនទៅប្រទេសដើម ខណៈដែលមនុស្សជាច្រើនផ្សេងទៀត កំពុងស្ថិតក្នុងដំណើរការនៃការបញ្ជូនត្រឡប់ទៅប្រទេសដើមវិញ។ លើសពីនេះ ចំនួន៤០៨ករណី ត្រូវបានបញ្ជូនទៅតុលាការ ខណៈដែលការស៊ើបអង្កេតបន្ថែមលើអ្នកជាប់ពាក់ព័ន្ធ និងកិច្ចខិតខំប្រឹងប្រែងក្នុងការស្វែងរកទ្រព្យសម្បត្តិខុសច្បាប់កំពុងបន្ត។

**ឯកឧត្តមទេសរដ្ឋមន្ត្រី**បានបញ្ជាក់ជាថ្មីថា ការអនុវត្តច្បាប់នឹងនៅតែម៉ឺងម៉ាត់ មានតម្លាភាព និងស្របនឹងនីតិវិធីត្រឹមត្រូវ ព្រមទាំងធានានូវការការពារផ្នែកច្បាប់សមស្របសម្រាប់ជនរងគ្រោះ និងការផ្តល់កិច្ចសហការ។ ឯកឧត្តមបានបញ្ជាក់បន្ថែមទៀតថា អាជ្ញាធរពាក់ព័ន្ធបន្តតាមដាន និងត្រួតពិនិត្យទីតាំងសង្ស័យ ដើម្បីបង្ការការប្រើប្រាស់ទីតាំងទាំងនោះសម្រាប់ការលេងល្បែងស៊ីសងតាមអ៊ីនធឺណិតខុសច្បាប់ ការក្លែងបន្លំ និងប្រតិបត្តិការឆបោក។ យុទ្ធនាការនេះក៏កំពុងត្រូវបានអនុវត្តរួមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយ ព្រមទាំង

ការចាត់វិធានការផ្លូវច្បាប់ប្រឆាំងនឹងមន្ត្រីដែលសង្ស័យថាមានជាប់ពាក់ព័ន្ធ ឬសម្របសម្រួលដល់សកម្មភាពឧក្រិដ្ឋកម្មនេះ។

ជាការវាយតម្លៃរួម **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានទទួលស្គាល់ថា ខណៈពេលដែលទីតាំងឆបោកធំៗទាំងអស់ត្រូវបានលុបបំបាត់ បណ្តាញឧក្រិដ្ឋជនបានសម្របខ្លួនដោយការផ្លាស់ប្តូរប្រតិបត្តិការទៅកាន់ទីតាំងតូចៗ និងរាយប៉ាយជាងមុន រួមមានផ្ទះសំណាក់ អចលនទ្រព្យជួល យានយន្ត និងហាងកាហ្វេ ដែលធ្វើឱ្យការស្វែងរកមានការលំបាក។ ហេតុដូចនេះ អាជ្ញាធរទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅតែមានការប្រុងប្រយ័ត្នក្នុងការកំណត់អត្តសញ្ញាណ និងលុបបំបាត់ប្រតិបត្តិការឆបោកនេះ ស្របពេលជាមួយគ្នានេះក៏ត្រូវលើកកម្ពស់ការយល់ដឹងរបស់សាធារណជន និងដោះស្រាយភាពចន្លោះប្រហោងនៃការអនុវត្តច្បាប់ ផងដែរ។

ជាទិសដៅខាងមុខ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានអំពាវនាវឱ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិដោយចីរភាព ជាពិសេសការចែករំលែកព័ត៌មាន កិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់ និងការកសាងសមត្ថភាព។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានបញ្ជាក់អំពីការត្រៀមខ្លួនរួចជាស្រេចរបស់កម្ពុជាក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអន្តរជាតិនានា ដើម្បីលុបបំបាត់បណ្តាញឧក្រិដ្ឋកម្មឆ្លងដែន និងទប់ស្កាត់ការកើតឡើងវិញ នៃសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យានេះ ទាំងក្នុង និងក្រៅប្រទេសកម្ពុជា។

បន្ទាប់ពីបទបង្ហាញ **លោកជំទាវ អ៊ាត សោភា** បានជម្រាបជូនអ្នកចូលរួមអំពីសន្និសីទអន្តរជាតិស្តីពីការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលនឹងប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ ពីថ្ងៃទី២៣-២៤ ខែកញ្ញា ឆ្នាំ២០២៦ ខាងមុខនេះ។ សន្និសីទដែលមានរយៈពេលពីរថ្ងៃនេះត្រូវបានគេរំពឹងថានឹងមានគណៈប្រតិភូចូលរួមប្រមាណ ៧០ ដែលរួមមានរដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់អាស៊ាន និងប្រទេសដទៃទៀត តំណាងមកពីស្ថាប័នអនុវត្តច្បាប់ និងសន្តិសុខ ព្រមទាំងអង្គការអន្តរជាតិផងដែរ។ សន្និសីទនេះនឹងលើកឡើងនូវការឆ្លើយតបរបស់តំបន់ និងសកលលោកចំពោះការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ភាពធន់ផ្នែកបច្ចេកវិទ្យា និងសាយប័រ ព្រមទាំងការចែករំលែកបទពិសោធន៍របស់ប្រទេសនីមួយៗ ក្នុងគោលបំណងបង្កើនការយល់ដឹងលើប្រព័ន្ធអេកូឡូស៊ី នៃការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាដែលកំពុងវិវត្ត ពង្រឹងការសម្របសម្រួលអន្តរជាតិ ក៏ដូចជាភាពជាដៃគូពហុភាគី និងផ្លាស់ប្តូរបទពិសោធន៍ និងឧត្តមានុវត្តន៍ សម្រាប់សកម្មភាពរួម ក្នុងការប្រឆាំងនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

ថ្ងៃសុក្រ ១៥កើត ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៦